ISSN 1560-7607 / ISBN 978-99950-52-05-8


# ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី១០ លេខ ៣ | កក្កដា - កញ្ញា ឆ្នាំ២០០៦ | តម្លៃ ១.៥០០៛


# បញ្ហាប្រឈមនៃកិច្ចរៀបចំការបោះឆ្នោតក្នុងបីខេត្ត នៅភាគខាងលិចប្រទេសកម្ពុជា

**ដួង វីរ័ត្ន ពិភាក្សាវែកញែកពីដំណើរការបោះឆ្នោតក្នុងបីខេត្ត ក្រោយពេលដែលកម្ពុជារៀបចំការបោះឆ្នោតបាន ៥លើក ចាប់តាំងពីឆ្នាំ១៩៩៣មក ។***



*ខប់សែល បានជួយធ្វើឱ្យការរៀបចំ និងដំណើរការបោះឆ្នោត កាន់តែមានតំលាភាព*

ប្រទេសកម្ពុជា បានធ្វើការបោះឆ្នោត ៥ លើកហើយ តាំងពីឆ្នាំ១៩៩៣មក គឺមានការបោះឆ្នោតថ្នាក់ជាតិ ៣លើក ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ១លើក និងការបោះឆ្នោតព្រឹទ្ធសភា ១លើក ។ ការបោះឆ្នោតសំខាន់ខ្លាំងណាស់ សំរាប់ការរីកចំរើនលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ការគោរពសិទ្ធិមនុស្ស និងកំណែលំអអភិបាលកិច្ចសំរាប់ការអភិវឌ្ឍន៍មានចីរភាព ។ម្យ៉ាងទៀត ការសិក្សាថ្មីមួយរបស់ វិបសអ ព្រមទាំងរបាយការណ៍ផ្សេងៗបានបង្ហាញថា តាំងពីឆ្នាំ១៩៩៨មក ការបោះឆ្នោតនៅកម្ពុជាកាន់តែមានគេទទួលស្គាល់ច្រើនថា មានលក្ខណៈសេរី និងយុត្តិធម៌[១] ។ ពិសេសជាងនេះ ការបោះឆ្នោតគឺកម្ពុជាជាអ្នកដំណើរការ និងគ្រប់គ្រងផ្ទាល់ដោយមានជំនួយបច្ចេកទេសតិចជាងមុនពីជំនាញការបរទេស ។ ប្រជាជនភាគច្រើនយល់ថា ការបោះឆ្នោតបានអនុវត្តឡើងដោយមានបទពិសោធន៍ច្បាស់លាស់ខាងបច្ចេកទេស ចំណាយតិចក្នុងការរៀបចំ និងក្របខ័ណ្ឌច្បាប់ដែលមានការកែលំអជាបន្តបន្ទាប់ ។

ទោះបីមានការរីកចំរើនដូច្នេះក្ដី ក៏នៅមានបញ្ហាចោទជាច្រើន ។ ក្រៅពីចន្លោះប្រហោងផ្សេងៗក្នុងក្របខ័ណ្ឌច្បាប់ ការបោះឆ្នោតតែងជួបការលំបាកនៃអំពើហិង្សាដែលមានទាំងទង្វើពិតៗ និងគ្រាន់តែជាការគំរាមកំហែង ការបំភិតបំភ័យ ការគៃបន្លំ និងរបៀបរបបមិនប្រក្រតី/មិនសមស្របផ្សេងៗ ។ កន្លងមកគណបក្សនយោបាយ ខ្វះវប្បធម៌ទុកចិត្តគ្នាក្នុងការពិភាក្សាពីបញ្ហាបោះឆ្នោត ដែលធ្វើឱ្យកាន់តែមានការខ្វែងមតិ និងទំនាស់ច្រើនថែមទៀត ។ បើចង់ឱ្យរបបប្រជាធិបតេយ្យពហុបក្សនៅកម្ពុជាអនុវត្តបានល្អ ត្រូវមានវេទិកាមួយដែលក្នុងនោះ អ្នកពាក់ព័ន្ធក្នុងការបោះឆ្នោតទាំងអស់ អាចពិភាក្សាពីការខ្វែងមតិ និងធ្វើការងារដើម្បីរកដំណោះស្រាយដោយសន្តិភាព ។

បច្ចុប្បន្ន នៅមានបញ្ហាទាក់ទិននឹងការបោះឆ្នោតជាច្រើន ដែលត្រូវដោះស្រាយ ។ ឧទាហរណ៍ ការទាល់ច្រកខាងនយោបាយរយៈ ១១ខែ ក្រោយពេលបោះឆ្នោតជាតិនៅខែកក្កដា ២០០៣ បានបង្កើនលទ្ធភាពឱ្យមានទំនាស់បោះឆ្នោត ការប្រឈមមុខយ៉ាងជូរចត់ និងការមិនទុកចិត្តគ្នាយ៉ាងជ្រាលជ្រៅនៅក្នុងចំណោមតួអង្គអ្នកនយោបាយនានា ។ ម្យ៉ាងវិញទៀត ថ្វីបើ

* ដួង វីរ័ត្ន ជាប្រធានកម្មវិធីសន្តិសុខមនុស្ស ការកសាងសន្តិភាព និងការបំប្លែងទំនាស់នៅ វិបសអ ។ អត្ថបទនេះ ផ្អែកលើការសិក្សាមួយរបស់អ្នកនិពន្ធ សំរាប់វគ្គសិក្សាស្ដីពីការវិភាគបញ្ហាអភិវឌ្ឍន៍របស់គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) ។ អ្នកនិពន្ធសូមអរគុណដល់បណ្ឌិត Brett Ballard នាយកស្រាវជ្រាវស្ដីទីនៅ វិបសអ លោក គីម សេតារា អ្នកស្រាវជ្រាវនៅ វិបសអ លោក ឱក សេរី សោភក្ដិ៍ ទីប្រឹក្សានិងអ្នកសំរបសំរួលយន្តការខប់សែល និងក្រុម ADI ចំពោះការជួយមតិ និងព័ត៌មានត្រឡប់ផ្សេងៗលើអត្ថបទ ។

## មាតិកា


បញ្ហាប្រឈមនៃកិច្ចរៀបចំការបោះឆ្នោត ........ ១
អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងបញ្ហាប្រឈមនៃរបប "កូនកាត់" ៥
កំណើនសេដ្ឋកិច្ចដ៏រឹងប៉ឹង និងការកែលំអវិធីសាស្ត្ររាយការណ៍ ........ ៩
បណ្ណាល័យ វិបសអ និង មណ្ឌលព័ត៌មានបឹងទន្លេសាប ........ ១៣
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស ........ ១៥
— ស្ថានភាពក្នុងប្រទេស ........ ១៧
— សន្ទស្សន៍សេដ្ឋកិច្ច ........ ២១
ព័ត៌មានថ្មីៗពី វិបសអ ........ ២៤

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គជប) បានទទួលការកោតសរសើរចំពោះលទ្ធផលការងារខាងបច្ចេកទេសក្ដី ក៏សាធារណជននៅតែចោទសួរពីឯករាជភាព និងភាពគួរឱ្យទុកចិត្តបានខាងនយោបាយរបស់ស្ថាប័ននេះ ។

ខប់សែល (យន្តការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា) គឺជាវេទិកាតុមូលមួយសំរាប់ការពិភាក្សាដោយចំហនិងត្រង់ទៅត្រង់មក លើបញ្ហាផ្សេងៗទាក់ទិននឹងការបោះឆ្នោត ។ យន្តការបានផ្តល់ជាវេទិកាអព្យាក្រិត និងមានសុវត្ថិភាព សំរាប់ការពិភាក្សាទល់មុខគ្នារវាងអ្នកតំណាងនានារបស់គណបក្សនយោបាយ រដ្ឋាភិបាល និងសង្គមស៊ីវិល អំពីបញ្ហាបោះឆ្នោត[២] ។ នៅក៏រិតជាតិ ខប់សែល ធ្វើការប្រជុំប្រចាំខែ ដែលមានការងាររៀបចំយ៉ាងច្រើនៈ ការរកមើលបញ្ហាត្រូវពិភាក្សា ការស្វែងរកចំនុចឯកភាពគ្នា ការកសាងជំនួយគាំទ្រ ការមូលមតិ ការតាមដានជាបន្ត និង ការពិភាក្សានៅក្រោយឆាក ។ គេមើលឃើញយន្តការនេះថា ជារចនាសម្ព័ន្ធមានចីរភាពល្អ សំរាប់ការកសាងទំនុកចិត្តតាមរយៈការពិភាក្សាដោយចំហ មានសុវត្ថិភាព និងក្នុងបរិយាកាសអព្យាក្រិត ។ ពីខែសីហា ១៩៩៩ ដល់ ការបោះឆ្នោតឆ្នាំ ២០០៣ ខប់សែល បានរៀបចំការប្រជុំ ៥០លើក ដោយមានអ្នកចូលរួមជាង ១០០នាក់ ដូចជា តំណាងសំខាន់ៗមកពីគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល (NGOs) ដែលឃ្លាំមើលការបោះឆ្នោត គជប ស្ថាប័នរក្សាសន្តិសុខ អង្គការនារី និងក្រសួងមហាផ្ទៃ ។ កំនត់ហេតុនៃការប្រជុំនីមួយៗក្រោយបានទទួលការឯកភាពពីអ្នកចូលរួមហើយ ត្រូវបានផ្ញើថ្វាយព្រះមហាក្សត្រ ផ្ញើជូនសមាជិកព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សាធម្មនុញ្ញ គជប នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទាំងអស់ដែលពាក់ព័ន្ធនឹងការបោះឆ្នោត អភិបាលនិងអភិបាលរងខេត្ត-ក្រុង ស្ថានទូតបរទេសប្រហែល ២៥ អង្គការអន្តរជាតិ និងអង្គការសង្គមស៊ីវិលផ្សេងៗ ។

សំរាប់ការបោះឆ្នោតក៏រិតជាតិនៅខែកក្កដា ២០០៣ ខប់សែល បានជួយឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាន ក្នុងគោលនយោបាយ និងដំណើរការបោះឆ្នោតតាមរយៈការពិភាក្សាលើប្រធានបទដូចជា ការពន្យារយៈពេលចុះបញ្ជីអ្នកបោះឆ្នោត នីតិវិធីមានតំលាភាព លទ្ធភាពស្មើភាពក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ កំណែលំអការអប់រំអ្នកបោះឆ្នោត ការរៀបចំនិងពង្រឹងសន្តិសុខ នីតិវិធីនិងការជ្រើសរើសគណៈកម្មការមានតំលាភាព ។ល។ ដោយមូលហេតុនេះ នៅកម្ពុជា (និងក្នុងតំបន់នេះ) មានការទទួលស្គាល់យ៉ាងទូលំទូលាយថា ខប់សែល គឺជាយន្តការសំរាប់បង្ការនិងគ្រប់គ្រងទំនាស់ និងជាវេទិកាមួយមានសុវត្ថិភាព និងអព្យាក្រឹតសំរាប់លើកកំពស់វប្បធម៌ពិភាក្សាគ្នា និងកសាងទំនុកចិត្តគ្នាទៅវិញទៅមក ។ គជប និង NGOs មួយចំនួនបានយកគំរូយន្តការនេះ ទៅដាក់បញ្ចូលក្នុងកម្មវិធីរបស់ខ្លួន ដើម្បីធ្វើការពិភាក្សាពីបញ្ហាដ៏ជាក់លាក់នានា ។

ដើម្បីបំរើដល់ការបោះឆ្នោតព្រឹទ្ធសភា ២០០៦ ការបោះឆ្នោតឃុំ-សង្កាត់ឆ្នាំ២០០៧ និងការបោះឆ្នោតក៏រិតជាតិឆ្នាំ២០០៨ វបសអ បានចាប់ដំណើរការ ខប់សែលដំណាក់កាលទី២ តាមរយៈសន្និសីទមួយនៅខែកក្កដា ២០០៥ ដើម្បីផ្តល់វេទិកាបើកចំហនិងអព្យាក្រឹត សំរាប់ការពិភាក្សាដោយមានសុវត្ថិភាពអំពីបញ្ហាបោះឆ្នោត ។ គោលដៅចំបងគឺ ការទប់ស្កាត់ទំនាស់ អំពើហិង្សា និងការយល់ច្រឡំផ្សេងៗ ដែលផុសឡើងនៅមុននិងក្នុងពេលបោះឆ្នោត តាមរយៈការកសាងទំនុកចិត្ត និងការជំរុញវប្បធម៌ពិភាក្សាគ្នា ដែលមានសារៈសំខាន់ជាមូលដ្ឋានដើម្បីកសាងសន្តិភាព និងរបបប្រជាធិបតេយ្យដែលចាស់ចិត្តចាស់គំនិតល្អ ។ ខប់សែលដំណាក់កាលទី២ នឹងមានដំណើរការ ៣ឆ្នាំ ដោយមានជំនួយហិរញ្ញវត្ថុពី UNDP ។

ការប្រជុំខប់សែលថ្នាក់ខេត្ត (COPCELPROM) មានទិសដៅចុះធ្វើការដល់ថ្នាក់ខេត្តដើម្បីបង្កើនការចូលរួមរបស់សាធារណជន ។ ការប្រជុំខប់សែលប្រព័ន្ធផ្សព្វផ្សាយ (COPCELMED) មានទិសដៅជំរុញឱ្យមានការចូលរួមយ៉ាងច្រើនរបស់ប្រជាជនក្នុងការបោះឆ្នោត ។ តាំងពីពេលចាប់ដំណើរការមកខប់សែលដំណាក់កាលទី២ បានរកឃើញបញ្ហាបោះឆ្នោតផ្សេងៗតែនៅក៏រិតជាតិប៉ុណ្ណោះ ។ រីឯបញ្ហាប្រឈមនៅក៏រិតខេត្ត គឺមិនទាន់រកឃើញទេ ហើយត្រូវតែរកឱ្យឃើញ និងដោះស្រាយឱ្យបានតាមរយៈការពិភាក្សាគ្នា ។

## វិធីសាស្ត្រស្រាវជ្រាវ

អត្ថបទនេះ ផុសចេញពីការចុះសិក្សាតូចមួយដល់មូលដ្ឋាន កាលពីថ្ងៃទី ១២-១៤ កក្កដា ២០០៦ ដោយប្រើប្រាស់សំនួរមានការណែនាំមួយចំនួន លើអ្នកផ្តល់ព័ត៌មាន ៣០នាក់ នៅខេត្តបាត់ដំបង ពោធិសាត់ និងកំពង់ឆ្នាំង នៅភាគខាងលិចប្រទេសកម្ពុជា ។ នៅតាមខេត្តនីមួយៗ អ្នកផ្តល់ព័ត៌មាន គឺមានអភិបាល រឺអភិបាលរងខេត្ត ស្នងការ រឺស្នងការរងនគរបាលខេត្ត ប្រធានគណៈកម្មការរៀបចំការបោះឆ្នោតខេត្ត ក្រុមការងារខេត្តរបស់គណបក្សប្រជាជន (CPP) ហ៊្វុនស៊ិនប៉ិច (FUNCINPEC) និង សម រង្ស៊ី (SRP) ប្រធានអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត (PLAU) តំណាងថ្នាក់ខេត្តរបស់អង្គការ ADHOC, COMFREL និង NICFEC ។ ការសិក្សាប្រឹងប្រែងស្វែងរកបញ្ហាបោះឆ្នោតចំបងៗ នៅតាមខេត្តដែលអាចយកមកធ្វើជាមូលដ្ឋានសំរាប់ការពិភាក្សា និងរកដំណោះស្រាយនៅក្នុងការប្រជុំខប់សែលថ្នាក់ខេត្ត ។ ការស្រាវជ្រាវ បានពិនិត្យពីចរិតនៃដំណើរការបោះឆ្នោត និងទំនាស់បោះឆ្នោតនៅក្នុងខេត្តទាំង ៣ ដោយផ្តោតការយកចិត្តទុកដាក់លើការចុះឈ្មោះបោះឆ្នោត ការឃោសនាបោះឆ្នោត និងដំណើរការនៅថ្ងៃបោះឆ្នោត ។

## ការចុះឈ្មោះអ្នកបោះឆ្នោត

ច្បាប់ស្តីពីការបោះឆ្នោតឃុំ-សង្កាត់ បានផ្ទេរការចុះឈ្មោះបោះឆ្នោតទៅឱ្យក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលក្នុងនាម គជប ត្រូវពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោតឡើងវិញ ចុះឈ្មោះអ្នកបោះឆ្នោតនៅក្នុងបញ្ជីបោះឆ្នោតសំរាប់ឃុំ-សង្កាត់នីមួយៗ ។ ដើម្បីបំពេញមុខងារនេះ ក្រុមប្រឹក្សាឃុំគួរប្រគល់វាទៅឱ្យស្មៀនឃុំ ដែលដើរតួនាទីជាមន្ត្រីពិនិត្យឡើងវិញនូវបញ្ជីឈ្មោះអ្នកបោះឆ្នោត និងជាអ្នកកាន់កាប់បញ្ជីនេះ ។ ក្រុមប្រឹក្សាឃុំត្រូវបញ្ជាអោយស្មៀនឃុំបំពេញការងារនេះឱ្យបានត្រឹមត្រូវ ទៅតាមច្បាប់បោះឆ្នោតព្រមទាំងបទប្បញ្ញត្តិ និងនីតិវិធីកំនត់ដោយ គជប[៣] ។ ច្បាប់ចែងថា បញ្ជីឈ្មោះអ្នកបោះឆ្នោតត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ ចាប់ពីខែតុលា ដល់ខែធ្នូនៃឆ្នាំនីមួយៗ ។ បញ្ជីឈ្មោះអ្នកបោះឆ្នោត ត្រូវចំលងជូន គជប ដែលមានភារកិច្ចផ្តល់សុពលភាពដល់បញ្ជីនេះឱ្យបានយ៉ាងតិច ៩០ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

យោងតាមខ្លឹមសារច្បាប់ ស្មៀនឃុំទទួលបន្ទុកចុះបញ្ជីអ្នកបោះឆ្នោតដោយមានការត្រួតពិនិត្យពីសមាជិកក្រុមប្រឹក្សាឃុំ[៤] ហើយបញ្ជីឈ្មោះអ្នកបោះឆ្នោតក៏មានការកែលំអយ៉ាងច្រើន ។ បញ្ជីមានលក្ខណៈកាន់តែត្រឹមត្រូវថែមទៀត តាមរយៈការលុបឈ្មោះអ្នកស្លាប់ និងអ្នកផ្លាស់ទីលំនៅចេញពីឃុំ ។

ជាគោលការណ៍ ការប្រគល់អំណាចទៅឱ្យអាជ្ញាធរឃុំកាន់កាប់បញ្ជីឈ្មោះអ្នកបោះឆ្នោត អាចជាវិធានការសមស្រប ពីព្រោះបានដាក់ថ្នាក់រដ្ឋបាល ដែល

សមស្របជាងគេឱ្យទទួលខុសត្រូវលើការងារនេះ[៥] ជាពិសេសនៅពេលដែលរដ្ឋាភិបាលកំពុងអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ[៦] ។

ការបែងចែកភារកិច្ចទៅឱ្យក៏រិតឃុំ ក៏អាចជួបគ្រោះថ្នាក់ដែរ ពីព្រោះក្រុមប្រឹក្សាឃុំទើបតែបង្កើតបានប្រហែលមួយឆ្នាំប៉ុណ្ណោះ នៅពេលដែលត្រូវបំពេញភារកិច្ចធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោតឆ្នាំ២០០២ ។ នៅក្នុងការសិក្សាដំបូងៗអំពីដំណើរការក្រុមប្រឹក្សាឃុំ មានការទទួលស្គាល់ជាទូទៅថា ក្រុមប្រឹក្សាឃុំមិនទាន់យល់ច្បាស់ល្អពីនីតិវិធី និងទិសដៅផ្ទាល់របស់ខ្លួនទេ ហើយក៏មិនទាន់ទទួលបានថវិកាសំរាប់បង្កើតប្រព័ន្ធផ្សេងៗដើម្បីជួយទ្រទ្រង់ដល់ភារកិច្ចរបស់ខ្លួនដែរ ។ ម្យ៉ាងទៀត ទំនាក់ទំនងរបស់ក្រុមប្រឹក្សាជាមួយប្រធាន និងស្មៀនរបស់ខ្លួន ព្រមទាំងទំនាក់ទំនងរវាងសមាជិកក្រុមប្រឹក្សាមកពី CPP និង SRP នៅទន់ខ្សោយនៅឡើយ ដោយខាង SRP មានអារម្មណ៍ថា ពួកខ្លួនត្រូវគេផាត់ចេញពីការធ្វើសេចក្តីសំរេចចិត្តផ្សេងៗ ។ ដោយមូលហេតុនេះ ទើបការធ្វើប្រតិភូកម្មសិទ្ធិអំណាចចុះឈ្មោះអ្នកបោះឆ្នោតទៅឱ្យថ្នាក់ឃុំ គឺជាការផ្ទេរការងារទៅអោយស្ថាប័នមួយដែលមានការរៀបចំ និង ការសំរបសំរួលនៅទន់ខ្សោយនៅឡើយ[៧] ។

ការសិក្សាក្នុង ៣ ខេត្តនៅភាគខាងលិច បានបង្ហាញដែរថា មានកំហិត និងការលំបាកមួយចំនួននៅក្នុងរយៈពេលចុះឈ្មោះបោះឆ្នោត ដោយសារភារកិច្ចផ្សេងៗដ៏មមាញឹកដែលថ្នាក់លើនៅក្រសួងមហាផ្ទៃ (MOI) បានដាក់ចុះឱ្យស្មៀនឃុំ បានរាំងរាំងពួកគេក្នុងការចុះឈ្មោះអ្នកបោះឆ្នោតឱ្យបានសកម្មល្អនៅក្នុងរយៈពេលចុះឈ្មោះត្រៀម ៩ខែ និងក្នុងរយៈពេល ២០ថ្ងៃនៃការចុះឈ្មោះបោះឆ្នោតជាផ្លូវការ ហើយស្មៀនឃុំបានយកលេសនេះទៅបំពេញភារកិច្ចផ្សេងៗទៀតវិញ ។ រឿងនេះជួនកាលធ្វើឱ្យប្រជាជនត្រូវរង់ចាំ ពីព្រោះនៅពេលមកចុះឈ្មោះបោះឆ្នោត គាត់រកស្មៀនឃុំមិនឃើញ ហើយក៏គ្មានព័ត៌មានអ្វីសោះ ។ ក្នុងពេលជាមួយគ្នា ក៏មានការងារជាច្រើន មកពីខាងសិលា និង NGOs ព្រមទាំងការធ្វើផែនការប្រចាំឆ្នាំរបស់ក្រសួងមហាផ្ទៃថែមទៀត ដែលកាន់តែធ្វើឱ្យយឺតយ៉ាវដល់សមាជិកក្រុមប្រឹក្សាឃុំ និងស្មៀនឃុំ ក្នុងការចុះឈ្មោះអ្នកបោះឆ្នោត ។

ស្មៀនឃុំនៅថ្មោងថ្មីនៅឡើយ ក្នុងរឿងនីតិវិធីចុះឈ្មោះអ្នកបោះឆ្នោត ដែលនាំឱ្យមានកំហុស និងការតវ៉ាជាច្រើនពីតំណាងគណបក្សនានា និង NGOs ។ យោងតាមបទសំភាសន៍ បញ្ហាភាគច្រើនទាក់ទិននឹងកំហុសក្នុងការសរសេរឈ្មោះ ថ្ងៃខែឆ្នាំ និងកន្លែងកំណើត ដោយសារការធ្វេសប្រហែសរបស់ស្មៀនឃុំ សមាជិកក្រុមប្រឹក្សាឃុំ រឺសាមីខ្លួនអ្នកបោះឆ្នោត ។

គេបានផ្តល់មតិថា ត្រូវមានការចូលរួមច្រើនថែមទៀត ក្នុងការលើកទឹកចិត្តប្រជាជនឱ្យបោះឆ្នោត ។ គណបក្សនយោបាយ NGOs និងអាជ្ញាធរមូលដ្ឋាន ជាពិសេសមេភូមិដែលទើបជ្រើសតាំងថ្មី គួរបំផុសប្រជាជនឱ្យយល់ពីសារៈសំខាន់នៃការបោះឆ្នោត ជាពិសេសការធានាឱ្យមានសិទ្ធិបោះឆ្នោតតាមរយៈការចុះឈ្មោះបោះឆ្នោត ។ អ្នកឆ្លើយសំភាសន៍ និងអ្នកចូលរួមក្នុងការប្រជុំខប់សែល បាននិយាយថា គ្រប់ៗគ្នាគួរធ្វើការឱ្យជិតស្និទ្ធជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គជប) គណៈកម្មការខេត្តរៀបចំការបោះឆ្នោត (គខប) និង គណៈកម្មការឃុំរៀបចំការបោះឆ្នោត (គឃប) ក្នុងការជៀសវាងការយល់ខុស ជាពិសេសទាក់ទិននឹងខ្លឹមសារនៃឯកសារអប់រំ ។

ប័ណ្ណបោះឆ្នោតពុំមានឱ្យប្រើទៀតទេ ក្នុងការបោះឆ្នោតលើកក្រោយ ដោយត្រូវប្រើអត្តសញ្ញាណប័ណ្ណផ្លូវការជាតិជំនួសវិញ[៨] ។ បើសិនអ្នកបោះឆ្នោតគ្មានអត្តសញ្ញាណប័ណ្ណនេះទេ អត្តសញ្ញាណប័ណ្ណមន្ត្រីរាជការ អត្តសញ្ញាណប័ណ្ណកងទ័ព រឺនគរបាល ក៏អាចប្រើប្រាស់ដើម្បីបោះឆ្នោតបានដែរ ។ ដំណោះស្រាយចុងក្រោយគឺ ទំរង់១០១៨ មានបិទរូបថត ដែលចេញដោយមេឃុំ អាចយកទៅប្រើដើម្បីបោះឆ្នោតបាន ។ ការផ្លាស់ប្តូរទៅប្រើអត្តសញ្ញាណប័ណ្ណវិញនេះ បានទទួលការលើកសរសើរពីអ្នកនយោបាយ និងស្ថាប័នជាច្រើន ពីព្រោះធ្វើដូច្នេះ ប្រជាជននឹងមានប័ណ្ណមួយ ដែលអាចប្រើការបានច្រើនយ៉ាង ហើយ គជប ក៏មិនចាំបាច់ចេញប័ណ្ណបោះឆ្នោតដែរ ។ ប៉ុន្តែ អ្នកនយោបាយខ្លះបានលើកពីការបារម្ភ ពីព្រោះអ្នកមានសិទ្ធិបោះឆ្នោតជាច្រើននាក់ពុំទាន់មានអត្តសញ្ញាណប័ណ្ណទេ ហើយដំណើរការចេញអត្តសញ្ញាណប័ណ្ណឱ្យប្រើប្រាស់វាយឺតយ៉ាវ និងមានអំពើពុករលួយផងក្នុងជួរនគរបាល[១០] ។ ក្នុងករណីខ្លះ អត្តសញ្ញាណប័ណ្ណអាចជាមធ្យោបាយមួយទៀតសំរាប់បំភិតបំភ័យសកម្មជនគណបក្ស ដោយគេមិនចេញអត្តសញ្ញាណប័ណ្ណឱ្យអ្នកណាដែលគាំទ្រគណបក្សផ្សេងពីគណបក្សដែលគាំទ្រដោយអាជ្ញាធរមូលដ្ឋាន ជាពិសេសក្រុម រឺថ្នាក់ដឹកនាំភូមិ ។

## ថ្ងៃឃោសនាបោះឆ្នោត

មេភូមិដើរតួនាទីយ៉ាងសំខាន់ ក្នុងការផ្សព្វផ្សាយព័ត៌មានបោះឆ្នោត ។ ប៉ុន្តែក៏មានការចោទប្រកាន់មេភូមិថា បានទិញសន្លឹកឆ្នោត ធ្វើការបំភិតបំភ័យដកហូតប័ណ្ណបោះឆ្នោត ធ្វើអំពើខុសច្បាប់ និងការគំរាមកំហែងជាច្រើនទៀតក្នុងរយៈពេលនៃការបោះឆ្នោត[១១] ។ ករណីបំភិតបំភ័យ ធ្វើឡើងដោយពួកមេឃុំ ដែលគាំទ្រគណបក្ស CPP មានគេលើកឡើងក្នុងខេត្តទាំង៣ នៃការសិក្សានេះ ហើយរូបភាពជាទូទៅ គឺមានការគំរាមកំហែងដល់សកម្មជននានាថានឹងរឹបអូសយកដី/ទ្រព្យសម្បត្តិ រឺធ្វើការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់អ្នកដែលគាំទ្រគណបក្សមួយផ្សេង ។ គេរាយការណ៍ថា នៅ "រាត្រីឆ្កែព្រុស" (គឺយប់មុនពេលបោះឆ្នោត ដែលតាមច្បាប់មិនត្រូវធ្វើការឃោសនាទេ) ពួកមេភូមិ រឺក្រុមអ្នកដឹកនាំផ្សេងទៀត បានដើរចុះឡើង ដើម្បីផ្តល់អំណោយ និងបញ្ចុះបញ្ចូលអ្នកបោះឆ្នោត ឱ្យគាំទ្រគណបក្សខ្លួន ។ ថ្វីបើតំណាងគណបក្សនៅតាមខេត្តបានលើកគ្រប់គ្នាពីរឿងនេះក្តី ប៉ុន្តែពុំមានគណបក្សណាមួយបានដាក់ពាក្យបណ្តឹងតវ៉ាជាផ្លូវការ ទៅជូនគណៈកម្មការខេត្តរៀបចំការបោះឆ្នោតទេ ។

## កិច្ចដំណើរការនៅថ្ងៃបោះឆ្នោត

នៅខេត្តទាំង ៣ មានគេរាយការណ៍យ៉ាងច្រើនពីករណីអ្នកបោះឆ្នោត ដែលរកមិនឃើញការិយាល័យបោះឆ្នោតរបស់ខ្លួននៅថ្ងៃបោះឆ្នោត ។ យោងតាមនីតិវិធី បើសិនចំនួនអ្នកបោះឆ្នោតកើនលើស ៧០០នាក់ នៅការិយាល័យបោះឆ្នោតណាមួយ ចំនួនលើសត្រូវផ្ទេរទៅការិយាល័យមួយផ្សេង ដើម្បីសំរាលការកកស្ទះ ។ ការផ្លាស់ប្តូរការិយាល័យបោះឆ្នោតបានធ្វើឱ្យអ្នកបោះឆ្នោតជាច្រើនច្រឡំបល់អស់ ពីព្រោះពួកគេតែងគិតថាបើចុះឈ្មោះនៅកន្លែងណា ត្រូវបោះឆ្នោតនៅកន្លែងនោះ ប៉ុន្តែទៅរកឈ្មោះមិនឃើញ ដូច្នេះហើយជួនកាលក៏លែងទៅបោះឆ្នោតតែម្តង ។ កំហុសក្នុងការសរសេរឈ្មោះ និងថ្ងៃខែឆ្នាំ ទីកន្លែងកំណើត ក៏មានញឹកញាប់ដែរក្នុងខេត្តទាំង ៣ ហើយប្រជាជន ក៏ត្រូវខកខានមិនបានបោះឆ្នោត ។ គណបក្សនយោបាយជាច្រើនបានប្តឹងតវ៉ាពីរឿងនេះ ដោយចោទថា វាមានគោលដៅរារាំងអ្នកគាំទ្ររបស់ពួកគេមិនឱ្យបោះឆ្នោតកើត ។

វត្តមានអាជ្ញាធរមូលដ្ឋាននៅខាងមុខការិយាល័យបោះឆ្នោត ក៏ត្រូវគេរាយការណ៍ថា បានជះឥទ្ធិពលមកលើអ្នកបោះឆ្នោត ជាពិសេសអ្នកដែលមិន

**សង្ខេបដំណើរការបោះឆ្នោត**

| ការចុះឈ្មោះអ្នកបោះឆ្នោត ត្រៀមរយៈពេល ៩ខែ | រយៈពេលចុះឈ្មោះបោះឆ្នោត ២០ថ្ងៃ | ការឃោសនាបោះឆ្នោត | ថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោត |
|---|---|---|---|
| ផ្ទេរការងារទៅឱ្យក្រុមប្រឹក្សាឃុំ និង ស្មៀនឃុំ ។ មានការកែលំអជាបន្តបន្ទាប់ ។ | ស្មៀនឃុំ អ្នកបោះឆ្នោត និងគជប ត្រូវគិតគូរឱ្យកាន់តែច្រើនលើភាពត្រឹមត្រូវខាងបច្ចេកទេស ជាពិសេស ពាក់ព័ន្ធនឹងបញ្ហាអក្ខរាវិរុទ្ធ និងការចុះថ្ងៃខែឆ្នាំ និងទីកន្លែងកំណើត ។ | ទំនាស់ភាគច្រើនកើតឡើង ដោយសារសកម្មជនគណបក្សមិនគោរពតាមកាលវិភាគដែលបានព្រមព្រៀង និងរំលោភលើក្រមសីលធម៌បោះឆ្នោត ។ រាត្រីឆ្កែព្រុស គេរាយការណ៍ថា ជារឿង ធម្មតានៅខេត្តបាត់ដំបង ពោធិសាត់ និងកំពង់ឆ្នាំង ។ | វត្តមានមេភូមិ មេឃុំ និង អភិបាលស្រុក នៅកន្លែងបោះឆ្នោតនៅតែជាបញ្ហាបារម្ភដ៏ធំមួយ ។ |

គាំទ្រគណបក្ស CPP ។ មេភូមិ មេឃុំ រឺអភិបាលស្រុក បានឈររង់ចាំនៅការិយាល័យបោះឆ្នោត ទោះបីពួកគេបានបោះឆ្នោតរួចក្តី ក្នុងរូបភាពមួយដើម្បីបំភិតបំភ័យដល់គណបក្សនយោបាយឯទៀត ។ គណបក្សទាំងនេះបានប្តឹងតវ៉ា ហើយ NGOs ដែលឃ្លាំមើលការបោះឆ្នោត ក៏កត់ត្រាពីរឿងនេះដែរ[១២] ។

## សេចក្តីសន្និដ្ឋាន

ការវាយតំលៃខ្នាតតូចនេះ បានបង្ហាញពីកំណែលំអក្នុងការបោះឆ្នោតនៅខេត្តបាត់ដំបង ពោធិសាត់ និងកំពង់ឆ្នាំង ។ ស្មៀនឃុំ ដែលទទួលបន្ទុកធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោត និងចុះបញ្ជីអ្នកបោះឆ្នោត គេយល់ដឹងកាន់តែច្រើនពីនីតិវិធីចុះបញ្ជីអ្នកបោះឆ្នោត និងយកចិត្តទុកដាក់ខ្លាំងជាងមុនអំពីដំណើរការបោះឆ្នោត ។ ចំនួនអ្នកមកចុះឈ្មោះបោះឆ្នោត កើនឡើងគួរឱ្យកត់សំគាល់ក្នុងឃុំភាគច្រើន ។ បញ្ហាសន្តិសុខ ក៏មានការកែលំអ ឆ្លងតាមកិច្ចសហប្រតិបត្តិការដ៏ល្អ រវាងមន្ត្រី គខប អាជ្ញាធរខេត្ត និងកងទ័ព ។ ការបំភិតបំភ័យ រឺអំពើហិង្សាលើសកម្មជនគណបក្សនយោបាយ ក៏ថយចុះដែរយោងតាមរបាយការណ៍ទទួលបាន ។

ចំពោះបញ្ហាចោទវិញ បច្ចុប្បន្ននៅមានមួយចំនួនមិនទាន់ដោះស្រាយទេ ។ ដោយឡែក ការងារដ៏ច្រើនដែលប្រគល់ទៅឱ្យស្មៀនឃុំ និងសមាជិកក្រុមប្រឹក្សាឃុំ នៅក្នុងអំឡុងពេលចុះបញ្ជីអ្នកបោះឆ្នោត បានធ្វើឱ្យយឺតយ៉ាវដល់ការចុះបញ្ជី និងបង្កការលំបាកដល់អ្នកបោះឆ្នោត និងស្មៀនឃុំ ។ គេបានលើកមតិថា ក្នុងរយៈ ២០ថ្ងៃ (០១-២០ តុលា) នៃការចុះបញ្ជីអ្នកបោះឆ្នោតជាផ្លូវការ គួរជៀសវាងលើកគំរោងធ្វើការងារឃុំអ្វីផ្សេងទៀត ដើម្បីទុកពេលឱ្យសមាជិកក្រុមប្រឹក្សាឃុំ និងស្មៀនឃុំ ផ្តោតកំលាំងលើការចុះបញ្ជីអ្នកបោះឆ្នោត ។ ក្នុងថ្ងៃមិនឱ្យឃោសនា នៅខេត្តទាំង៣ មានគេរាយការណ៍ជាទូទៅពី "រាត្រីឆ្កែព្រុស" ដែលបង្ហាញថា គណបក្សនយោបាយនានា នៅតែព្យាយាមចែកអំណោយឱ្យអ្នកគាំទ្រដដែល ។

វត្តមានមេភូមិ និងមេឃុំនៅតាមការិយាល័យបោះឆ្នោត ក្រោយពេលពួកគាត់បានបោះឆ្នោតហើយ នៅតែជាចំនុចបារម្ភមួយសំរាប់គណបក្សនយោបាយ និង NGOs អន្តរជាតិ ពីព្រោះវាអាចជាការបំភិតបំភ័យដល់អ្នកបោះឆ្នោត ។ ដើម្បីដោះស្រាយរឿងនេះ ត្រូវមានកិច្ចសហប្រតិបត្តិការរវាងគណបក្សនយោបាយនានា ដើម្បីកុំឱ្យដំណើរការបោះឆ្នោតមានរូបភាពមិនល្អ ។ ចំពោះនីតិវិធីបច្ចេកទេស និងការចុះបញ្ជីអ្នកបោះឆ្នោត ត្រូវតែយកចិត្តទុកដាក់ច្រើនថែមទៀត ជាពិសេសអក្ខរាវិរុទ្ធ ថ្ងៃខែឆ្នាំ និង ទីកន្លែងកំណើត ត្រូវតែត្រឹមត្រូវច្បាស់លាស់ ។ ក្នុងករណីត្រូវផ្លាស់ប្តូរការិយាល័យបោះឆ្នោតត្រូវផ្សព្វផ្សាយព័ត៌មានឱ្យបានទូលំទូលាយ ដើម្បីជៀសវាងការរអាក់រអួល នៅថ្ងៃបោះឆ្នោត ។

## កំណត់សំគាល់

១. C. Hughes and Kim S. (2004), *The Evolution of Democratic Process and Conflict Management in Cambodia,* CDRI, and UNDP (March 2002), *Report on the Election of the Commune Council*. Speech by SAR Kheng, deputy prime minister and minister of the interior, speech by IM Suosdey, chairperson of the National Election Committee, speech by Douglas Gardner, UNDP representative and UN resident coordinator, all at the Meeting on Calling for Funding for 2007 Commune Election, Cambodiana Hotel, 8 June 2006.

២. ការសិក្សារបស់ វិបសអ ស្តីពីចរិត និងមូលហេតុនៃទំនាស់ក្នុងការបោះឆ្នោត ឆ្នាំ១៩៩៨ បានលើកអនុសាសន៍ឱ្យបង្កើតខប់សែលឡើង ។ ចំពោះព័ត៌មានបន្ថែមស្តីពីរចនាសម្ព័ន្ធ និងសកម្មភាពខប់សែល សូមមើលក្នុងវេបសាយរបស់ វិបសអៈ www.cdri.org.kh

៣. ច្បាប់បោះឆ្នោតតំណាងរាស្ត្រ អនុម័តឆ្នាំ២០០២ (ជំពូក៦ មាត្រា៥៣)

៤. របាយការណ៍ដោយ ទេព នីថា អគ្គលេខាធិការ គជប ក្នុងការប្រជុំខប់សែលប្រចាំខែនៅភ្នំពេញ (សូមមើលកំណត់ហេតុខប់សែលដាក់លើ www.cdri.org.kh) ហើយនិងបទសំភាសន៍នានាសំរាប់ការសិក្សានេះ ។

៥. C. Hughes and Kim S. (2004), *The Evolution of Democratic Process and Conflict Management in Cambodia* (Phnom Penh: CDRI), p. 57.

៦. សុន្ទរកថាដោយ អ៊ឹម សួស្តី, *op. cit.*

៧. C. Hughes and Kim S. *op. cit.,* p. 58,

៨. របាយការណ៍ដោយ ទេព នីថា ក្នុងការប្រជុំខប់សែលនៅភ្នំពេញ ។ សូមមើលកំណត់ហេតុប្រជុំខប់សែល មានដាក់ក្នុងវេបសាយរបស់ វិបសអ : www.cdri.org.kh

៩. ទំរង់ចេញឱ្យដោយមេឃុំនេះសំរាប់បញ្ជាក់ថា អ្នកកាន់ឯកសារជានិវាសនជន នៅក្នុងឃុំ និងមានសិទ្ធិបោះឆ្នោត បើសិនគាត់គ្មានឯកសារផ្លូវការអ្វីផ្សេងសំរាប់បញ្ជាក់ ។

១០. បទសំភាសន៍សំរាប់ការសិក្សានេះ ។

១១. C. Hughes and Kim S. *op. cit.*

១២. C. Hughes and Kim *S. op. cit.,* and interviews for this study.